# ជំពូក មួយៈ សេចក្តីផ្តើម

## ១.១. ទស្សនៈវិស័យជាសកល :

យោងតាមអង្គការ ILO មានគ្រោះថ្នាក់ការងារច្រើនជាង ២៥០លាន ករណីរាល់ៗឆ្នាំ ។ បន្ថែមលើនេះទៀត មានការប៉ាន់ស្មានថា កម្មករនិយោជិតជាង ១៦០លាននាក់ធ្លាក់ខ្លួនឈឺក្នុងមួយឆ្នាំៗ តាមរយៈការទទួលរងហានិភ័យ នៅតាមកន្លែងធ្វើការ ហើយច្រើនដល់ទៅ ១,២ លាននាក់ស្លាប់ដោយសារគ្រោះថ្នាក់នៅកន្លែងធ្វើការនិងជំងឺ ។ តថភាពជាក់ស្តែង គឺថាសោហ៊ុយចំណាយខាងសង្គមកិច្ច និង ខាងមនុស្សទៅលើផលិតកម្ម គឺអស់ថ្លៃយ៉ាងខ្ពស់រហូត ដល់មិនអាចទទួលយកបាន ។ តាមទស្សនៈខាងសេដ្ឋកិច្ចមានការប៉ាន់ស្មានថា ការខាតបង់ប្រចាំឆ្នាំដែលបណ្តាលមកពី គ្រោះថ្នាក់នៅកន្លែងធ្វើការនិងជំងឺ គឺប្រហែលជាស្មើនឹង ៤% នៃផលទុនជាតិសរុប (GNP)។ តួលេខទាំងនេះគិត រួមទាំងការចំណាយដោយផ្ទាល់ និង ដោយប្រយោលទៅលើគ្រោះថ្នាក់និងជំងឺមានជាអាទិ៍ ការចំណាយផ្នែកពេទ្យ ការខាតបង់ពេលវេលាធ្វើការ ការបន្ថយផលិតកម្ម តាវ៉កាលិក ការបណ្តុះបណ្តាល និង ការបណ្តុះបណ្តាលឡើងវិញ សំរាប់កម្មករនិយោជិត ការខូចខាតសំភារៈបរិក្ខារ និង ការជួសជុល ការធ្លាក់ទឹកចិត្តរបស់បុគ្គលិក ការផ្សព្វផ្សាយ ដំណឹងមិនល្អជាដើម ។

ក្នុងពេលកន្លងទៅ តួលេខបែបនេះមានឥទ្ធិពលតិចតួចទៅលើមនុស្ស មានជាអាទិ៍តួលេខអំពីគ្រោះថ្នាក់ សុខភាពមិនល្អនៅក្នុងការងារ គឺតែងតែត្រូវបានគេមើលឃើញថាជាផ្នែក និងជាចំណែកមួយនៃផលិតកម្ម ហេតុអ្វីត្រូវ ផ្លាស់ប្តូរ ជាពិសេសបើមានកម្មករនិយោជិតជាច្រើនដែលគ្មានការងារធ្វើរង់ចាំនៅក្រៅរបងរោងចក្រសុំដាក់ពាក្យធ្វើ ការ? ការខាតបង់ប្រភេទនេះគិតទៅគឺមិនអាចជៀសផុតឡើយ ទោះជាគិតខាងផ្នែកហិរញ្ញវត្ថុ ឬខាងមនុស្សក្តី ។ ប៉ុន្តែ ពេលវេលាបានផ្លាស់ប្តូរដោយនិយោជក ថៅកែរោងចក្រ កម្មករនិយោជិត និងរដ្ឋាភិបាលកំពុងតែទទួលស្គាល់ច្រើន ឡើងៗថា ការចំណាយខាងសង្គមកិច្ច និងខាងសេដ្ឋកិច្ចទៅលើជំងឺ និងគ្រោះថ្នាក់នៅកន្លែងធ្វើការគឺខ្ពស់ពេកមិនអាច ទទួលយកបាន ហើយបានដាក់បន្ទុកយ៉ាងធ្ងន់ទៅលើភាពប្រកួតប្រជែងរបស់សហគ្រាស និងទៅលើសុខមាលភាព នៃសេដ្ឋកិច្ចរបស់ប្រទេស ។ ភាពសមស្របទៅតាមបទដ្ឋានការងារអន្តរជាតិ ច្បាប់ជាតិ និងការអនុវត្តន៍ ព្រមទាំង ក្រមនៃឧស្សាហកម្មនៅថ្នាក់រោងចក្រសហគ្រាស ឥឡូវនេះត្រូវបានគេមើលឃើញថា ជាល័ក្ខខ័ណ្ឌតម្រូវជាចាំបាច់ ដំបូងគេមួយសំរាប់ក្រុមហ៊ុនទំនើបទទួលបានជោគជ័យ ។ ការកែលំអឱ្យប្រសើរនូវសុខភាព និងសុវត្ថិភាពការងារ គឺស្ថិតក្នុងផលប្រយោជន៍ល្អបំផុតនៃបណ្តាភាគីពាក់ព័ន្ធទាំងអស់ពោលគឺ រដ្ឋាភិបាល និយោជក និង កម្មករនិយោជិត ហើយទាមទារឱ្យមានការពិគ្រោះយោបល់គ្នា ការសហការ និងការប្តេជ្ញាចិត្តពីគ្រប់បណ្តាភាគីពាក់ព័ន្ធទាំងអស់ ។ សុខភាពល្អ និងការគ្រប់គ្រងសុវត្ថិភាព ព្រមទាំងការប្រតិបត្តិផ្នែកសុវត្ថិភាព បង្កើតនូវមូលដ្ឋានគ្រឹះមួយក្នុងចំណោម មូលដ្ឋានគ្រឹះនានាសំរាប់ជោគជ័យនៃការធ្វើអាជីវកម្ម ។ មូលដ្ឋានគ្រឹះនេះគឺជាវត្ថុមួយជំរុញស្មារតីក្រុមហ៊ុនជាច្រើន ។ ការបោះពុម្ពផ្សាយសៀវភៅណែនាំនាពេលនេះគឺត្រូវបានបធ្វើឡើងដើម្បីជួយរោងចក្រនៅក្នុងវិស័យកាត់ដេរនៅកម្ពុជា ឱ្យសំរេចបាននូវបំណងប្រាថ្នានេះ ។ គ្មានការបង្រួមសេចក្តីចំពោះការកែលំអសុខភាព និងសុវត្ថិភាពនៅកន្លែងធ្វើការ

ទេ ប្រការនេះត្រូវគេមើលឃើញថាជាផ្នែកមួយនៃគោលគំនិតស្ដីពីការគ្រប់គ្រងគុណភាពទាំងស្រុង[២០] តាមរយៈគោលគំនិតនេះ "វិធីប្រតិបត្តិដ៏ល្អបំផុតផ្នែកសុវត្ថិភាព និងសុខភាព ត្រូវបានគេរៀបចំអនុវត្តនៅក្នុងខ្សែផលិត" ជាជាងពឹងផ្អែកទាំងស្រុងទៅលើ "ការពិនិត្យផលិតខូចគុណភាពដែលផលិតចេញមក"។ ក្រុមហ៊ុនដែលទទួលជោគជ័យទាំងនៅក្នុងមូលដ្ឋានជាតិ និងក្នុងមូលដ្ឋានអន្តរជាតិបានទទួលស្គាល់យ៉ាងច្បាស់ថា ជំងឺ និងគ្រោះថ្នាក់នៅកន្លែងធ្វើការឱ្យខាតបង់ប្រាក់ ហើយថាប្រព័ន្ធប្រកបដោយប្រសិទ្ធិភាពសំរាប់គ្រប់គ្រងសុខភាព និងសុវត្ថិភាពដែលមានរាប់បញ្ចូលទាំងកម្មករនៅក្នុងខ្សែផលិតកម្មផង នឹងជួយកាត់បន្ថយសោហ៊ុយចំណាយ បង្កើនផលិតភាព និងផ្ដល់ប្រយោជន៍ដល់កម្មករនិយោជិត និង សង្គមទាំងមូល ។

## ១.២ តើសៀវភៅណែនាំនេះអាចជួយភាគីពាក់ព័ន្ធឱ្យកែលំអសុវត្ថិភាព និងអនាម័យការងារនៅកន្លែងធ្វើបាន ដូចម្ដេចខ្លះ

បើលោកអ្នកជានាយក ឬ ថៅកែរោងចក្រកាត់ដេរ ឬ ជាសមាជិកនៃគណៈកម្មការរួមទទួលបន្ទុកផ្នែកសុវត្ថិភាព និងសុខភាព ប្រការសំខាន់គឺត្រូវទប់ស្កាត់តាំងពីដំបូងទី ដោយធ្វើការដោះស្រាយបញ្ហាផ្នែកសុវត្ថិភាព និងសុខភាពដែលត្រូវគេមើលឃើញថា ជាផ្នែកស្នូលនៃការគ្រប់គ្រង ពុំមែនជាផ្នែកនៃជំរើសបន្ថែមទេ ។ ក្រុមហ៊ុនដែលទទួលបានជោគជ័យ បានទទួលស្គាល់ជាយូរមកហើយថា សុខភាព និងសុវត្ថិភាព គឺជាការទទួលខុសមួយរបស់គណៈគ្រប់គ្រង ហើយមានសារៈសំខាន់ស្មើគ្នានឹងផលិតកម្ម និងគុណភាព។ បទដ្ឋានជាតិ និងបទដ្ឋានអន្តរជាតិគូសបញ្ជាក់ទាំងស្រុងថា វាជាភារកិច្ចរបស់និយោជកត្រូវផ្ដល់ឱ្យមានបរិយាកាសការងារប្រកបដោយសុវត្ថិភាព និងសុខភាពល្អ។ ដូចគ្នានេះដែរអ្នកបញ្ជាទិញជាច្រើនដូចជា Adidas, Gap, H&M និង Nike កំពុងតែទទូចតាមរយៈក្រមសីលធម៌របស់ខ្លួនឱ្យចាត់ទុកថា សុខភាព និង សុវត្ថិភាពការងារ គឺជាអាទិភាពមួយ ។ ការផ្សព្វផ្សាយមិនល្អជាមួយពត៌មានអំពីផលិតកម្មដោយ "ហាងកេងប្រវ័ញ្ចកំលាំងពលកម្ម" នៅក្នុងប្រទេសតតិយលោក ហើយជាលទ្ធផលធ្វើឱ្យការលក់ធ្លាក់ចុះ បានន័យថាអ្នកទិញទំនិញឥឡូវនេះកំពុងទទូចឱ្យរោងចក្រអនុវត្តសមស្របតាមបទដ្ឋានស្នូលដែលមានរួមបញ្ចូលទាំងសុខភាព និងសុវត្ថិភាពការងារផង។ ចំពោះរោងចក្រតាមមូលដ្ឋាននានា ប្រការនេះគឺជាបញ្ហានៃការអនុវត្តន៏សមស្របតាមបទដ្ឋានស្នូលទាំងនេះ ឬក៏សុខចិត្តបាត់កិច្ចសន្យា ។

ចំពោះនាយក និង ថៅកែខ្លះ ការប្ដេជ្ញាចិត្តកែលំអល័ក្ខខ័ណ្ឌការងារ អាចត្រូវមើលឃើញថាជាការចំណាយមិនចាំបាច់ តើហេតុអ្វីត្រូវចំណាយប្រាក់នៅពេលដែលផលចំណេញរកបានយ៉ាងតឹងតែង នៅពេលដែលការប្រកួតប្រជែងទាំងនៅក្នុងប្រទេសកម្ពុជា និង អន្តរជាតិ (ចិន បង់ក្លាដេស ស្រីលង្កា ។ល។) មានសភាពខ្លាំងក្លា នៅពេលដែលថៅកែមកពីបរទេសមិនចង់វិនិយោគរយៈពេលវែង នៅពេលដែលច្បាប់ជាតិខ្សោយ ហើយមិនសូវបានគេអនុវត្ត និងនៅពេលដែលកំលាំងពលកម្មមានការយល់ដឹងតិចតួចអំពីបញ្ហាសុខភាព និងសុវត្ថិភាព? បើទោះណាជាវិស័យនេះមានភាពសំខាន់ចំពោះសេដ្ឋកិច្ចក្ដី ក៏រោងចក្រកាត់ដេរមួយចំនួនមិនរីកចំរើន ឬរស់រាននៅក្នុងទីផ្សារសកល

---

[២០] ការគ្រប់គ្រងសុវត្ថិភាព និងសុខភាពប្រកបដោយជោគជ័យ របស់គណៈកម្មការប្រតិបត្តិ ផ្នែកសុវត្ថិភាព និងសុខភាព នៅចក្រភពអង់គ្លេស ឆ្នាំ ១៩៩២

លោកដែលមានការប្រកួតប្រជែងយ៉ាងខ្លាំងនេះដែរ ។

ដូចដែលយើងនឹងឃើញនៅក្នុងសៀវភៅណែនាំនេះ រោងចក្រកាត់ដេរនិមួយៗនៅកម្ពុជាមានបញ្ហាខ្លះផ្នែក សុខភាព និង សុវត្ថិភាព ។ សៀវភៅណែនាំនេះផ្តល់គោលការណ៍ណែនាំអំពីរបៀបធ្វើអោយប្រសើរនូវសុខភាព និង សុវត្ថិភាពនៅក្នុងរោងចក្ររបស់លោកអ្នក ដើម្បីអោយរោងចក្រអាចបំពេញតាមបទដ្ឋានជាតិ និងបទដ្ឋានអន្តរជាតិ។ សៀវភៅនេះបង្ហាញចេញសំណូមពរមួយឈុតអាចយកទៅអនុវត្តបាន ហើយអស់សោហ៊ុយចំណាយតិចសំរាប់កែលំអ ល័ក្ខខ័ណ្ឌ និងបង្កើនផលិតភាព។ ជាសារវ័ន្ត សៀវភៅណែនាំនេះជួយលោកអ្នកអោយបង្កើតបាននូវកន្លែងធ្វើការ មួយប្រកបដោយសុខភាព និងសុវត្ថិភាពជាងមុន ។

## ១.៣ រចនាសម្ព័ន្ធនៃសៀវភៅណែនាំ

សៀវភៅណែនាំនេះត្រូវបានសរសេរក្នុងទំរង់ងាយស្រួលប្រើ និង ងាយស្រួលអនុវត្ត ដោយមានរួមបញ្ចូល ផ្នែកបច្ចេកទេសនានាដូចខាងក្រោមនេះ :

- សេចក្តីផ្តើម
- គោលនយោបាយ និង ការអនុវត្តន៍
- ល័ក្ខខ័ណ្ឌការងារទូទៅ
- សីតុណ្ហភាព ខ្យល់ចេញចូល សំលេង និង ភ្លើងបំភ្លឺ
- ធូលីក្រខ្វក់នៃវត្ថុធាតុគីមី ផ្សែង និង ចំហាយ
- ការរៀបចំប្លង់ប៉ុស្តិ៍ការងារ
- ការបំពាក់របាំងការពារគ្រឿងម៉ាស៊ីន
- សុវត្ថិភាពអគ្គីសនី
- សុវត្ថិភាពអគ្គីភ័យ
- សុខមាលភាព
- បញ្ជីផ្ទៀងផ្ទាត់ និង ការធ្វើផែនទីហានិភ័យ

ផ្នែកនិមួយៗមានសេចក្តីសង្ខេបអំពីចំណុចសំខាន់ៗ ហើយតាមការចាំបាច់ចំពោះមុខ មានសេចក្តីសង្ខេបអំពី "ក្បួនខ្នាតបុរាណ" ខ្លះៗដើម្បីជួយមិត្តអ្នកអានឱ្យយល់អំពីរឿងរ៉ាវទាំងនោះ ។ ផ្នែកនិមួយៗរៀបចំឡើងដោយមាន ផ្នែកផ្សំដូចខាងក្រោមនេះ :

- សេចក្តីណែនាំជាទូទៅ
- ពតិមានស្នូល
- បញ្ជីផ្ទៀងផ្ទាត់

- សេចក្តីសង្ខេប

ផ្នែកទាំងនេះត្រូវបានសរសេរដើម្បីផ្តល់ពត៌មានពិតនៅក្នុងដៃជូនដល់នាយក កម្មករនិយោជិត សមាជិកនៃគណៈកម្មការរួមទទួលបន្ទុកផ្នែកសុវត្ថិភាព និងសុខភាព និងអ្នកតាមឃ្លាំមើលរបស់អង្គការ ILO ដើម្បីជួយពួកគេកែលំអឱ្យប្រសើរនូវសុវត្ថិភាព និងអនាម័យការងារនៅក្នុងរោងចក្ររបស់ពួកគេ។ គំរូខ្លះៗនៃការអនុវត្តន៍ល្អៗ និងរូបថតមួយចំនួនដែលបានថតនៅតាមរោងចក្រកាត់ដេរផ្សេងៗត្រូវបានដាក់បញ្ចូល ដើម្បីបង្ហាញអំពីចំណុចសំខាន់ជាគន្លឹះ។ ផ្នែកនិមួយៗត្រូវបានបង្កើតឡើងជាមួយនឹងបញ្ជីផ្ទៀងផ្ទាត់ដែលនឹងជួយដល់មិត្តអ្នកអានឱ្យចេះពិនិត្យមើលរោងចក្រក្នុងលក្ខណៈជាប្រព័ន្ធ ។

ផ្នែកចុងក្រោយដែលស្តីពីបញ្ជីផ្ទៀងផ្ទាត់ និងការធ្វើផែនទីហានិភ័យផ្តល់នូវគោលការណ៍ណែនាំដល់មិត្តអ្នកអានអំពីរបៀបរៀបចំកន្លែងធ្វើការទាំងមូល និងកំណត់អាទិភាពលើផ្នែកនានាដែលជាបញ្ហាកង្វល់ដែលទាមទារការយកចិត្តទុកដាក់ ។

## ១.៤ ឯកសារយោងផ្សេងៗ

បទដ្ឋានពាក់ព័ន្ធមួយចំនួនរបស់អង្គការ ILO ស្តីពីសុវត្ថិភាព និង អនាម័យការងារ (អនុសញ្ញា និងអនុសាសន៍) មានយោងសំអាងនៅក្នុងអត្ថបទទាំងមូល ដូចគ្នានឹងសេចក្តីយោងតាមបទបញ្ញាសំខាន់ៗស្តីពីសុវត្ថិភាព និងសុខភាពរបស់ប្រទេសកម្ពុជាផងដែរ ដូច្នេះអ្នកអានអាចយល់ដឹងពីការតម្រូវដោយបទដ្ឋានជាតិ និងដោយបទដ្ឋានអន្តរជាតិ។ ឯកសារយោងផ្សេងទៀតនឹងត្រូវប្រើ ដើម្បីចង្អុលបង្ហាញផ្នែកផ្សំផ្សេងៗទៀតតាមការចាំបាច់។ ក្នុងចំណោមឯកសាយោងពាក់ព័ន្ធមួយចំនួន គឺមានអត្ថបទរបស់អង្គការ ILO មានជាអាទិ៍ :

- អនុសញ្ញារបស់ ILO ស្តីពីសុវត្ថិភាព និង អនាម័យការងារ C155 (1981)
- អនុសាសន៍របស់ ILO ស្តីពីសុវត្ថិភាព និង អនាម័យការងារ R164 (1981)
- អនុសញ្ញារបស់ ILO ស្តីពីសេវាអនាម័យការងារ C161 (1985)
- អនុសាសន៍របស់ ILO ស្តីពីសេវាអនាម័យការងារ R171 (1985)
- របាយការណ៍របស់អគ្គនាយក ILO ស្តីពីការងារសមរម្យ សន្និសីទអន្តរជាតិស្តីពីវិស័យការងារ សម័យប្រជុំលើកទី 87 (1998) ។
- គោលការណ៍ណែនាំរបស់ILO ស្តីពីប្រព័ន្ធគ្រប់គ្រងសុវត្ថិភាព និងអនាម័យការងារILO-OSH (2001) ។
- គោលការណ៍គ្រឹះរបស់ ILO ស្តីពីប្រព័ន្ធគ្រប់គ្រងសុវត្ថិភាព និងអនាម័យការងារ B.Alli (2001) ។
- ការកែលំអលក្ខខ័ណ្ឌការងារ និង ផលិតភាពនៅក្នុងឧស្សាហកម្មកាត់ដេររបស់ ILO ដោយ J.C Hiba (1998) ។
- សៀវភៅបណ្តុះបណ្តាលសំរាប់អធិការការងាររបស់ ILO ដោយ A. Vahapassi (2003) ។